# សេចក្តីថ្លែងការណ៍

*អង្គការ-សមាគមខ្មែរកម្ពុជាក្រោម* មានសេចក្តីសោកស្តាយយ៉ាងខ្លាំង ចំពោះសេចក្តីសំរេចលេខ *៥០២/ ០៧ ស.ន.ក.ជ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៧របស់សម្តេចព្រះសង្ឃនាយកក្នុងករណីចាប់ផ្សឹកព្រះតេជព្រះគុណ* **ទឹម សាខន** ព្រះចៅអធិការវត្តភ្នំឌិន ខាងជើង ឃុំភ្នំដិន ស្រុកគីរីវង់ ខេត្តតាកែវកាលពីថ្ងៃទី៣០ ខែមិថុនា ឆ្នាំ ២០០៧ ។

សេចក្តីសំរេចនេះ ផ្ទុយទាំងស្រុងទៅនិងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៤៣ បានចែងជាអាទិ៍ថា *"......ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ"* និងព្រះវិន័យសង្ឃក្នុងពុទ្ធសាសនាដែលបានចែងថា *"ព្រះសង្ឃក្នុងព្រះពុទ្ធសាសនាដែលអាចចាប់ផ្សឹកបាន លុះត្រាណាតែសង្ឃអង្គនោះបានប្រព្រឹត្តល្មើសសិក្ខាបទណាមួយក្នុងសិក្ខាបទទាំង ៤ នៃអាបត្តិបារាជិក"* ។

យោងតាមមូលហេតុនៃសេចក្តីសំរេចរបស់សម្តេចសង្ឃនាយក ដែលបានចោទប្រកាន់ព្រះតេជគុណ**ទឹម សាខន** ថា បានធ្វើសកម្មភាពបំបែកបំបាកសាមគ្គីភាពកម្ពុជា-វៀត ណាម រហូតឈានទៅដល់ការចាប់ផ្សឹក ទាំងកំរោល នោះមិនបានស្ថិតនៅក្នុងសិក្ខាបទណាមួយនៃអាបត្តិបារាជិកទាំង ៤នោះទេ ។

*អង្គការ-សមាគមខ្មែរកម្ពុជាក្រោម*មើលឃើញថា ព្រះតេជព្រះគុណ ***ទឹម សាខន*** មិនមានសមត្ថភាពធ្វើអោយប៉ះពាល់ដល់មិត្តភាព-សាមគ្គីភាព វៀតណាម-កម្ពុជាម៉ឺនឆ្នាំនោះឡើយ ។

*អង្គការ-សមាគមខ្មែរកម្ពុជាក្រោម*សូមអំពាវនាវៈ

១ អង្គការជាតិ អន្តរជាតិមេត្តាចូលរួមធ្វើការស៊ើបអង្កេតករណីចាប់ផ្សឹកព្រះតេជគុណ**ទឹម សាខន** ជាបន្ទាន់ ។

២ សូមសម្តេចព្រះសង្ឃនាយក និងស្ថាប័នពាក់ពន្ធ័បង្ហាញភស្តុតាងជាសាធារណៈ និងបញ្ជាក់អំពីទំហំនៃការខូចខាតដល់មិត្តភាពកម្ពុជា-វៀតណាម អោយបានច្បាស់លាស់ ដើម្បីជៀសវាងការថ្កោលទោសថាស្ថាប័នសង្ឃព្រះពុទ្ធសាសនានៅព្រះរាជាណា ចក្រកម្ពុជា ជាអាយ៉ងដាច់ថ្លៃរបស់អាជ្ញាធរវៀតណាម ។

៣ សូមបំបួសព្រះតេជគុណ **ទឹម សាខន** ឡើងវិញជាបន្ទាន់ ពីព្រោះព្រះអង្គពុំបានប្រព្រឹត្តប្រាសចាកធម៌វិន័យព្រះពុទ្ធសាសនាឡើយ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០០៧

**១ សមាគមព្រះសង្ឃខ្មែរកម្ពុជាក្រោម**

**ប្រធាន**

ព្រះមហា **យឿង សិន**

012 918 692

**២ សហគមន៍ខ្មែរកម្ពុជាក្រោម**

**ប្រធាន**

លោក **ថាច់ សេដ្ឋា**

012 908 882

៣ គណៈកម្មការសម្របសម្រួលខ្មែរកម្ពុជាក្រោម

ប្រធាន

លោក គឹម ចណ្ណនេច

016 232 119

៤ អង្គការខ្មែរកម្ពុជាក្រោម ការពារសិទ្ធិមនុស្ស

នាយកប្រតិបត្តិ

លោក អាង ចន្ទ័ឫទ្ធិ

012 934 802

៥ សម្ព័ន្ធសមណនិស្សិត និស្សិតខ្មែរកម្ពុជាក្រោម

ប្រធាន

ព្រះគ្រូ ចៅ សាង

012 992 470

៦ សមាគមខ្មែរកម្ពុជាក្រោមដើម្បីសិទ្ធិមនុស្ស និងអភិវឌ្ឍន៍

នាយកប្រតិបត្តិ

លោកសឺន ឈឿង

012 933 649

៧ អង្គការខ្មែរកម្ពុជាក្រោមដើម្បីកុមារ

ប្រធាន

ថាច់ តាក់ប៉ូ

៨ សមាគមខ្មែរកម្ពុជាក្រោមនិង អភិវឌ្ឍន៍

ប្រធាន

ថា. ប៊ុនថន

012901604.

៩ អង្គការស្ត្រីខ្មែរកម្ពុជាក្រោម

ប្រធាន

អ្នកស្រី ព្រំ យ៉ាង

011 636 012

១០ មូលនិធិសំរាប់អ្នកក្រីក្រ

ប្រធាន

យេង ចាវ

១១ សមាគមខ្មែរកម្ពុជាក្រោម

ប្រធាន

លោក លឹម រាន

012. 885769

១២ មិត្តសមាគមខ្មែរកម្ពុជាក្រោម

ប្រធាន

លោក ថាច់ សាង

012 58 63 36